# អង្គការទស្សនៈពិភពលោក

# ទិវាជាតិអំណាន

# ១១ មិនា ២០១៦

## សេចក្តីថ្លែងការណ៍សាធារណៈស្តីពី ការធ្វើឱ្យបណ្ណាល័យបឋមសិក្សាមានភាពប្រសើរឡើង ដើម្បីបង្កើនទំលាប់អានរបស់កុមារកម្ពុជា

ស្របពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រារព្ធពិធីជាតិអំណានដើម្បីបង្កើនទំលាប់អានទូទាំងប្រទេស អង្គការទស្សនៈពិភពលោក បានចេញផ្សាយការសិក្សាខ្លីមួយស្តីពី**ស្ថានភាពនិងការប្រើប្រាស់បណ្ណាល័យបឋមសិក្សានាពេលបច្ចុប្បន្ន៖ សង្ខេបការអង្កេតក្នុងខេត្តប្រាំក្នុងប្រទេសកម្ពុជា**។ ការសិក្សានេះបានបង្ហាញពីតម្រូវការក្នុងការបង្កើនការផ្តោតការយកចិត្តទុកដាក់លើបណ្ណាល័យដើម្បីធ្វើឱ្យប្រសើរឡើងនូវការអាននិងការសិក្សា។ គុណភាពអប់រំក្នុងប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយ។ វង្វាយតម្លៃអំណានថ្នាក់ដំបូង (EGRA) បានបង្ហាញថាសិស្សថ្នាក់ទី២ចំនួនមួយភាគបីមិនអាចអានសូម្បីតែមួយពាក្យ។

ការសិក្សាមួយចំនួននៅប្រទេសផ្សេងៗបានរកឃើញនូវទំនាក់ទំនងដ៏ខ្លាំងមួយរវាងបណ្ណាល័យដែលមានការគ្រប់គ្រងល្អនិងបំពាក់ធនធានសម្បូរបែប ជាមួយនឹងការកើនឡើងនូវអត្រានៃការអាននិងលទ្ធផលនៃការសិក្សារបស់សិស្សានុសិស្ស។ នៅឆ្នាំ២០១១ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើត និងដាក់ឲ្យប្រើប្រាស់នូវ **ស្តង់ដារបណ្ណាល័យបឋមសិក្សា** ដើម្បីធានាឲ្យបណ្ណាល័យកាន់តែមានគុណភាពនិងប្រសិទ្ធិភាពខ្ពស់សម្រាប់ការសិក្សានិងការបង្រៀននៅកម្រិតបឋមសិក្សា។ បើទោះបីជាការដាក់ឱ្យប្រើប្រាស់ស្តង់ដារបណ្ណាល័យនេះពិតជានាំមកនូវបណ្ណាល័យកាន់តែច្រើនមានដំណើរការប្រសើរជាងមុននៅទូទាំងប្រទេសកម្ពុជាក៏ដោយ ក៏ការសិក្សាថ្មីនេះបានរកឃើញភាពខ្វះចន្លោះមួយចំនួនក្នុងការអនុវត្តន៍ស្តង់ដារទាំងនេះ។

សាលាបឋមសិក្សាចំនួន ២៤ ក្នុងខេត្ត ៥ ត្រូវបានអង្កេតផ្ទៀងផ្ទាត់ជាមួយស្តង់ដារបណ្ណាល័យចំនួន១០។ មានតែបណ្ណាល័យមួយប៉ុណ្ណោះដែលអនុលោមតាមស្តង់ដារទាំង១០។ ៥៨% អនុលោមបានត្រឹមតែពាក់កណ្តាលនៃស្តង់ដារ ហើយក្រៅពីនោះអនុលោមបានតិចជាងពាក់កណ្តាលនៃស្តង់ដារ។

ការសិក្សាខ្លីនេះក៏បានរកឃើញថា មានសាលាដែលបានអង្កេតតែ៦២%ប៉ុណ្ណោះដែលមានចំនួនបណ្ណារក្សត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់ បើទោះបីជាបណ្ណារក្សទាំងនោះមិនបានទទួលការបណ្តុះបណ្តាលចាំបាច់ស្តីពីការគ្រប់គ្រងបណ្ណាល័យក៏ដោយ។ ការសិក្សានេះក៏បានបង្ហាញផងដែរថា ថ្វីត្បិតតែសិស្សានុសិស្សជាញឹកញាប់អាចប្រើប្រាស់បណ្ណាល័យបានក៏ដោយ ក៏ពួកគេមិនសូវទទួលបានសកម្មភាពនានាដែលជម្រុញការអានដែលមានសារៈសំខាន់សម្រាប់ការសិក្សារបស់ពួកគេឡើយ (ដូចជា ការនិទានរឿង ល្បែងសិក្សា ឬសកម្មភាពសិល្បៈ)។ កង្វះធនធានសិក្សាក៏ត្រូវបានរកឃើញ ដោយមានតែសាលា២៥%ប៉ុណ្ណោះដែលមានសៀវភៅនិងធនធានអំណានគ្រប់គ្រាន់ស្របតាមស្តង់ដារ។

អង្គការទស្សនៈពិភពលោកសូមទទួលស្គាល់និងអបអរសាទររាជរដ្ឋាភិបាលកម្ពុជាចំពោះវឌ្ឍនភាពដ៏ល្អៗដែលសម្រេចបាន ក្នុងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធអប់រំ និងអត្រាចូលរៀនរបស់សិស្ស។ ក្នុងការស្វាគមន៍ដល់កិច្ចដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការប្រារព្ធទិវាជាតិអំណានលើកទី១នេះ អង្គការទស្សនៈពិភពលោកក៏សូមអំពាវនាវរាជរដ្ឋាភិបាលឱ្យ៖

១. បង្កើនការគាំទ្រផ្នែកថវិកានិងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការងារវាយតម្លៃនិងគ្រប់គ្រងបណ្ណាល័យបន្ថែមទៀត តាមរយៈផែនការច្បាស់លាស់ដើម្បីធានាថាសាលាទាំងអស់មានបរិក្ខាបណ្ណាល័យ និងធានាការអនុលោមតាមស្តង់ដារបណ្ណាល័យ ជាពិសេសសម្រេចបាននូវចំនួនបណ្ណារក្សទទួលបានការបណ្តុះបណ្តាលដូចមានចែងក្នុងគោលនយោបាយ ហើយបង្កើនចំនួនសៀវភៅសិក្សាគោលនិងធនធានអំណានសម្រាប់សិស្សានុសិស្ស។

២. បង្កើនការបណ្តុះបណ្តាលជំនាញដល់បណ្ណារក្ស។ ជំហ៊ានដំបូងគឺធានាថាបណ្ណារក្សដែលមានស្រាប់ទទួលបានការបណ្តុះបណ្តាលអប្បបរមានូវវគ្គបណ្តុះបណ្តាលដែលមានចែងក្នុងគោលនយោបាយ ហើយជំហ៊ានបន្ទាប់គឺផ្តោតការបណ្តុះបណ្តាលទៅលើបច្ចេកទេសនិងយុទ្ធសាស្ត្រដើម្បីរៀបចំសកម្មភាព បណ្ណាល័យដែលមានលក្ខណៈច្នៃប្រឌិតនិងមានការចូលរួម។

៣. តម្រូវឱ្យបណ្ណារក្សបង្កើតនិងបង្កើនការអនុវត្តន៍លើការកត់ត្រាការប្រើប្រាស់បណ្ណាល័យរបស់សិស្សានុសិស្សនិងរក្សាកំណត់ត្រាខ្ចីសៀវភៅ។

៤. គាំទ្រសាលាឱ្យបង្កើនកិច្ចប្រឹងប្រែងដើម្បីជម្រុញការខ្ចីសៀវភៅ។ កិច្ចប្រឹងប្រែងនេះអាចមានការបង្កើនភាពញឹកញាប់នៃការចូលបណ្ណាល័យ ការធ្វើលំហាត់អំណានជាក្រុម អំណានឮ និងការនិទានរឿង (ជាជាងគ្រាន់តែលើកទឹកចិត្តការអានសៀវភៅដោយខ្លួនឯង)។